# និយ័តករគណនេយ្យនិងសវនកម្ម

## ព្រឹត្តិបត្រព័ត៌មានប្រចាំខែវិច្ឆិកា ឆ្នាំ២០២៤

លេខ:០១១

សេចក្តីសង្ខេបព័ត៌មាន និងព្រឹត្តិការណ៍សំខាន់ៗប្រចាំខែវិច្ឆិកា របស់និយ័តករគណនេយ្យ និងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រួមមានដូចខាងក្រោម៖

### កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២០



១.កាលពីថ្ងៃចន្ទ ៤កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែវិច្ឆិកា គ.ស.២០២៤ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគា បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី២០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា** អ.ស.ហ ដែលបានប្រព្រឹត្តទៅនៅសាលប្រជុំធំ នៃទីស្តីការ **អ.ស.ហ.**។

### កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ




២.កាលពីថ្ងៃចន្ទ ១១កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែវិច្ឆិកា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោកស្រីនាន បូនី** អគ្គនាយករង និងលោកស្រី **ហា សុគន្ធា** ប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុបានចូលរួមកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បី "ពិនិត្យនិងពិភាក្សាលើរបាយការណ៍

## ព័ត៌មានថ្មីៗ


កិច្ចប្រជុំក្រុមប្រឹក្សា សូមអាននៅទំព័រ......................១
កិច្ចប្រជុំគណៈកម្មាធិការ សូមអាននៅទំព័រ..............១
កិច្ចប្រជុំលើកទី៤ សូមអាននៅទំព័រ........................២
កិច្ចប្រជុំទ្វេភាគី សូមអាននៅទំព័រ.........................៣
វគ្គបណ្តុះបណ្តាលស្តីពី សូមអាននៅទំព័រ................៣
វេទិកាស្រាវជ្រាវ សូមអាននៅទំព័រ..........................៤
សិក្ខាសាលាបណ្តុះបណ្តាល សូមអាននៅទំព័រ..........៤
វេទិកាអន្តរជាតិ សូមអាននៅទំព័រ..........................៤
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ.........................៥
សិក្ខាសាលាពិគ្រោះយោបល់ សូមអាននៅទំព័រ.........៥
កិច្ចប្រជុំលើកទី៤១ សូមអាននៅទំព័រ......................៦
កិច្ចប្រជុំក្រុមការងាររាជរដ្ឋាភិបាល សូមអាននៅទំព័....៦
សិក្ខាសាលាពិគ្រោះយោបល់ សូមអាននៅទំព័..........៧
ពិនិត្យនិងផ្តល់យោបល់ សូមអាននៅទំព័រ................៧
កិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សា សូមអាននៅទំព័រ......៨
ជួបសម្តែងការគួរសម សូមអាននៅទំព័រ........................៩
កិច្ចប្រជុំលើកទី២ សូមអាននៅទំព័រ........................៩
ជួបពិភាក្សា សូមអាននៅទំព័រ...............................៩
សិក្ខាសាលាបញ្ច្រាប សូមអាននៅទំព័រ.................១០
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ.......................១០
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ.......................១១
កិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សា សូមអាននៅទំព័រ...១១
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ......................១២
កិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សា សូមអាននៅទំព័រ...១២
កិច្ចប្រជុំពិគ្រោះយោបល់ សូមអាននៅទំព័រ...........១៣
ទទួលជួបពិភាក្សាការងារ សូមអាននៅទំព័រ..........១៣
សិក្ខាសាលាផ្សព្វផ្សាយស្តីពី សូមអាននៅទំព័រ........១៤
កម្មវិធីវិបស្សនា សូមអាននៅទំព័រ.......................១៤
សិក្ខាសាលាពិគ្រោះយោបល់ សូមអាននៅទំព័រ.......១៥


© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

សមិទ្ធកម្មប្រចាំត្រីមាសទី៣ ឆ្នាំ២០២៤ ដំណាក់កាលទី៤" តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**។ កិច្ចប្រជុំនេះបានពិភាក្សាលើរបៀបវារៈចំនួន២ រួមមាន៖ ១.បទបង្ហាញអំពីវឌ្ឍនភាពនៃការអនុវត្តលទ្ធផលគន្លឹះនៃផ្នែកទាំង៥ ប្រចាំត្រីមាសទី៣ ឆ្នាំ២០២៤ និង២.ផ្សេងៗ។

## កិច្ចប្រជុំលើកទី៤ របស់គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា




៣.កាលពីថ្ងៃសុក្រ ១កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១ ខែវិច្ឆិកា គ.ស.២០២៤ **ឯកឧត្តម ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា បានដឹកនាំកិច្ចប្រជុំលើកទី៤ របស់គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា (គ.ក.គ.ក.) ដោយមានការអញ្ជើញចូលរួម **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាអនុប្រធានប្រចាំការនៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជាព្រមទាំងមានការចូលរួមពីសមាជិកនិងលេខាធិការដ្ឋាន របស់គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា (គ.ក.គ.ក.) ដើម្បីពិនិត្យនិងសម្រេចលទ្ធផលប្រឡងលើកទី១ របស់កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជាតាមប្រព័ន្ធអនឡាញ។

## កិច្ចប្រជុំទ្វេភាគីជាមួយគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្ម



៤.កាលពីថ្ងៃសុក្រ ១កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១ ខែវិច្ឆិកា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពស់ខ្ពង់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ស៊ុន ស៊ឹម** ប្រធានការិយាល័យអាជ្ញាបណ្ណ និង**លោកម៉ាច់ ដារ៉ា** អនុប្រធានការិយាល័យនីតិកម្មនិងដោះស្រាយវិវាទ បានចូលរួមកិច្ចប្រជុំទ្វេភាគីជាមួយគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្ម ដើម្បីប្រជុំពិគ្រោះយោបល់លើ សេចក្តីព្រាងប្រកាសស្តីពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យល្បែងពាណិជ្ជកម្ម នៅសាលប្រជុំនៃអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ក្នុងគោលបំណងប្រមូលធាតុចូលបន្ថែមលើសេចក្តីព្រាងប្រកាសឱ្យកាន់តែពេញលេញគ្រប់ជ្រុងជ្រោយនិងមានសង្គតិភាពជាមួយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## វគ្គបណ្តុះបណ្តាលស្តីពីមូលដ្ឋានគ្រឹះគណនេយ្យមុននឹងសិក្សាស្តង់ដាគណនេយ្យ




៥.កាលពីថ្ងៃចន្ទ៤កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែវិច្ឆិកា គ.ស.២០២៤ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ**លោក ឈាង ឆេងហាន** អនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព បានចូលរួមបើកវគ្គបណ្តុះបណ្តាលស្តីពី "មូលដ្ឋានគ្រឹះគណនេយ្យមុននឹងសិក្សាស្តង់ដាគណនេយ្យ" ដែលមានរយៈពេល៣ថ្ងៃ នៅអគារ ៣៤៥។ វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងនៅក្នុងគោលបំណងដើម្បីបញ្ជ្រាបការយល់ដឹងអំពីមូលដ្ឋានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្តោតទៅលើផ្នែកសំខាន់ៗដែលមូលដ្ឋានមុននឹងឈានទៅសិក្សាវគ្គស៊ីជម្រៅគឺវគ្គស្តង់ដារបាយការណ៍ទាក់ទងនិងហិរញ្ញវត្ថុអន្តរជាតិកម្ពុជា សម្រាប់សហគ្រាសធុននិងមធ្យម (CIFRS For SMEs) និងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា(CIFRS)។

## វេទិកាស្រាវជ្រាវ ABACUS របស់ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិឆ្នាំ២០២៤



៦.កាលពីថ្ងៃចន្ទ ៤កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែវិច្ឆិកា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព **លោក ទឹម សត្យា** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយកដ្ឋានកិច្ចការទូទៅ និង **លោក ហេង សំណាង** ប្រធានការិយាល័យស្តង់ដាគណនេយ្យសាធារណៈ នៃនាយកដ្ឋានបច្ចេកទេស បានចូលរួម "វេទិកាស្រាវជ្រាវ ABACUS របស់ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិឆ្នាំ២០២៤" ដែលបានសហការរៀបចំឡើងដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ(IASB) និងស្ថាប័នបោះផ្សាយ ABACUS ចាប់ពីថ្ងៃទី៤-៥ ខែវិច្ឆិកា គ.ស.២០២៤ នៅសាកលវិទ្យាល័យស៊ីដនី ទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី។

## សិក្ខាសាលាបណ្តុះបណ្តាលស្តីពី "អភិបាលកិច្ចសាជីវកម្មនៃសហគ្រាសសាធារណៈ"



៧.កាលពីថ្ងៃអង្គារ ៥កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែវិច្ឆិកា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ **លោក ជឿន រតនា** និង **លោក អ៊ិន បូផា អេលីត** មន្ត្រីជំនាញ បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពី "អភិបាលកិច្ចសាជីវកម្មនៃសហគ្រាសសាធារណៈ" ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី៥-៦ ខែវិច្ឆិកា គ.ស.២០២៤ នៅសណ្ឋាគារសុខា ខេត្តសៀមរាប។ សិក្ខាសាលាបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម អៀង ស៊ុនលី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងគោលបំណងផ្សព្វផ្សាយអំពីការងារកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈនៅកម្ពុជា និងបញ្ជ្រាបការយល់ដឹងពីទស្សនទានទូទៅ និងឧត្តមានុវត្តន៍ជាអន្តរជាតិ ពាក់ព័ន្ធនឹងម៉ូដែលនៃការគ្រប់គ្រងសហគ្រាសសាធារណៈ។

## វេទិកាអន្តរជាតិ "Singapore Fintech Festival 2024"



៨.កាលពីថ្ងៃពុធ ៦កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៦ ខែវិច្ឆិកា គ.ស.២០២៤ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោកស្រី ថៅ សេដ្ឋចាន់លីដា** អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ **លោក ជីវ ហ៊** ប្រធានការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យា និងមន្ត្រីជំនាញ បានចូលរួមវេទិកាអន្តរជាតិ "Singapore Fintech Festival 2024" ដែលប្រព្រឹត្តទៅនៅប្រទេសសិង្ហបុរី។ វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) របស់សិង្ហបុរីគឺជាទំនាក់ទំនងសកលដែលមានសហគមន៍គោលនយោបាយហិរញ្ញវត្ថុនិងបច្ចេកវិទ្យាបញ្ចូលគ្នា រៀបចំឡើងដើម្បីជំរុញទំនាក់ទំនង និងការសហការប្រកបដោយប្រសិទ្ធភាព។ SFF គឺជាវេទិកាមួយដើម្បីស្វែងយល់ពីចំណុចប្រសព្វនៃដំណោះស្រាយហិរញ្ញវត្ថុពាក់ព័ន្ធនឹងទិដ្ឋភាពបទប្បញ្ញត្តិ និងនវានុវត្តន៍បច្ចេកវិទ្យាចុងក្រោយ។

## កិច្ចប្រជុំពិភាក្សាជាមួយជំនាញការរបស់សហភាពអឺរ៉ុប អំពីតម្រូវការទីប្រឹក្សាបច្ចេកទេសរបស់និយ័តករគណនេយ្យនិងសវនកម្ម




៩.កាលពីថ្ងៃសុក្រ ៨កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៨ ខែវិច្ឆិកា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ហេង សំណាង** ប្រធានការិយាល័យស្តង់ដាគណនេយ្យសាធារណៈ និងមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំពិភាក្សាជាមួយជំនាញការរបស់សហភាពអឺរ៉ុប អំពីតម្រូវការទីប្រឹក្សាបច្ចេកទេសរបស់និយ័តករគណនេយ្យនិងសវនកម្ម សម្រាប់គាំទ្រការអនុវត្តសកម្មភាពកែទម្រង់គន្លឹះក្រោមក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤"។

## សិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ"



១០.កាលពីថ្ងៃសុក្រ ៨កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៨ ខែវិច្ឆិកា គ.ស.២០២៤ នៅសណ្ឋាគារហៃយ៉ាត់រីជិនស៊ីភ្នំពេញ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក សឿន បូតេ** អនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព និងមន្ត្រីជំនាញ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត មី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ.** ដោយមានការចូលរួមពីនិយ័តករក្រោមឱវាទ អ.ស.ហ. និង**អ្នកឧកញ៉ា គិត ម៉េង** ប្រធានសភាពាណិជ្ជកម្មកម្ពុជា និងជាប្រធានក្រុមការងារផ្នែកសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងសមាជិកសភាពាណិជ្ជកម្មកម្ពុជា។

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

## កិច្ចប្រជុំលើកទី៤១ នៃក្រុមការងារអ្នកជំនាញការអន្តររដ្ឋាភិបាលស្ដីពីស្តង់ដាគណនេយ្យ និងការរាយការណ៍អន្តរជាតិ ដែលបានបង្កើតឡើងដោយ ECOSOC នាឆ្នាំ១៩៨៣




១១.កាលពីថ្ងៃពុធ ៦កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៦ ខែវិច្ឆិកា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម បានដឹកនាំគណៈប្រតិភូរបស់និយ័តករគណនេយ្យនិងសវនកម្ម ដើម្បីចូលកិច្ចប្រជុំលើកទី៤១ នៃក្រុមការងារអ្នកជំនាញការអន្តររដ្ឋាភិបាលស្តីពីស្តង់ដាគណនេយ្យ និងការរាយការណ៍អន្តរជាតិ ដែលបានបង្កើតឡើងដោយ ECOSOC នាឆ្នាំ១៩៨៣។ កិច្ចប្រជុំនេះប្រព្រឹត្តទៅរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី៦-៨ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ដែលប្រទេសកម្ពុជាបានក្លាយជាសមាជិកនៃស្តង់ដាគណនេយ្យនិងការរាយការណ៍អន្តរជាតិ (International Standard of Accounting and Reporting) ចាប់ពីថ្ងៃទី១ ខែមករា គ.ស.២០២៤។ កិច្ចប្រជុំក្រុមការងារអន្តររដ្ឋាភិបាលបានផ្តោតសំខាន់ទៅលើប្រធានបទសំខាន់ចំនួន២៖ ១.ការត្រួតពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តនិងការរាយការណ៍ព័ត៌មានចីរភាព, ការអះអាង និងក្រមសីលធម៌ (Review of progress in harmonization and practical implementation of sustainability reporting, assurance and ethical considerations) ២.ការរួមបញ្ចូលការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុ និងព័ត៌មានចីរភាពនៃស្ថាប័ន ដោយប្រើប្រាស់បច្ចេកវិទ្យា (Integrating reporting on the financial and sustainability performance of entities: Leveraging digitalization)។ សូមជម្រាបផងដែរថា កម្ពុជានឹងត្រៀមខ្លួនអនុវត្តស្តង់ដាការរាយការណ៍ព័ត៌មានចីរភាពដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា ឆ្នាំ២០១៦-២០៣០។

## កិច្ចប្រជុំក្រុមការងាររបស់រាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលដោះស្រាយសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល



១២.កាលពីថ្ងៃចន្ទ ១១កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ត្រូវនឹងថ្ងៃទី១១ ខែវិច្ឆិកា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពស់ខ្ពស់ពី **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក សឿន បូតេ** អនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព អមដោយ **លោក យាន ផល្លា** ប្រធានការិយាល័យអនុលោមភាពទី៣ និង**លោកស្រី ឆាន់ ចេត្តនា** អនុប្រធានការិយាល័យអនុលោមភាពទី៣ បានចូលរួមកិច្ចប្រជុំក្រុមការងាររបស់រាជរដ្ឋាភិបាលដើម្បីសម្របសម្រួលដោះស្រាយសំណើ និងសំណូមពរ របស់អង្គការ

សង្គមស៊ីវិលនៅសាលប្រជុំខេត្តកំពត នៃទីស្តីការក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ុន ហុន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាប្រធានក្រុមការងារ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាអនុប្រធាន និងសមាជិកនៃក្រុមការងារ ព្រមទាំងមន្ត្រីតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធផងដែរ។

## សិក្ខាសាលាពិគ្រោះយោបល់ស្តីពីសេចក្តីព្រាងក្របខ័ណ្ឌតាមដាន និងវាយតម្លៃសេដ្ឋកិច្ច និងធុរកិច្ចឌីជីថលកម្ពុជា



១៣.កាលពីថ្ងៃអង្គារ ១២កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែវិច្ឆិកា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពស់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោកស្រី ហៅ សេដ្ឋចាន់លីដា** អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ អមដោយ **លោក ជ រ័ត្ននា** អនុប្រធានការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យា បានចូលរួម "សិក្ខាសាលាពិគ្រោះយោបល់ស្តីពីសេចក្តីព្រាងក្របខ័ណ្ឌតាមដាននិងវាយតម្លៃសេដ្ឋកិច្ច និងធុរកិច្ចឌីជីថលកម្ពុជា ក្រោមក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥" នៅសណ្ឋាគារអូកវូដព្រេមៀ ភ្នំពេញ (Oakwood Premier Phnom Penh) ដែលរៀបចំដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល (គ.ស.ធ.ឌ.) និងមានការចូលរួមពីតំណាងក្រសួង-ស្ថាប័ន និងមន្ត្រីផ្នែកបច្ចេកទេសពាក់ព័ន្ធចំនួន៨៧ រូប។ សិក្ខាសាលាពិគ្រោះយោបល់នេះរៀបចំឡើងក្នុងគោលបំណងសំខាន់ៗចំនួន២ គឺ៖ ១.ពិភាក្សាពីការរៀបចំសូចនាករតាមដាននិងវាយតម្លៃស្តីពីការកសាងមូលដ្ឋានគ្រឹះនិងការចាប់យកឌីជីថល (២០២១ - ២០២៥) និងប្រមូលធាតុចូលបឋមពីក្រសួង-ស្ថាប័នទទួលបន្ទុកអនុវត្តពាក់ព័ន្ធនឹងពង្រាងបញ្ជីសូចនាករនិង។ ២.ពិគ្រោះយោបល់លើសេចក្តីព្រាងផែនការសកម្មភាព៣ឆ្នាំរំកិល ២០២៥-២០២៧ របស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល។

## ពិនិត្យនិងផ្តល់យោបល់លើ "សេចក្តីព្រាងនីតិវិធីប្រតិបត្តិស្តង់ដាស្តីពីការស៊ើបអង្កេត និងការដាក់ទណ្ឌកម្មវិន័យ របស់វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា




១៤.កាលពីថ្ងៃពុធ ១៣កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី ១៣ ខែវិច្ឆិកា គ.ស.២០២៤ នៅបន្ទប់ប្រជុំធំនិយ័តករគណនេយ្យនិងសវនកម្ម **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យ

និងសវនកម្ម អមដោយ **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព បានដឹកនាំមន្ត្រីជំនាញ ពិនិត្យនិងផ្តល់យោបល់លើ "សេចក្តីព្រាងនីតិវិធីប្រតិបត្តិស្តង់ដាស្តីពីការស៊ើបអង្កេតនិងការដាក់ទណ្ឌកម្មវិន័យរបស់វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (វ.គ.ស.ក.)" ។

## កិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាលើ "សេចក្តីព្រាងបឋមគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃសន្និធិ




១៥.កាលពីថ្ងៃចន្ទ ៣រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែវិច្ឆិកា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ហេង សំណាង** ប្រធានការិយាល័យស្តង់ដាគណនេយ្យសាធារណៈ អមដោយមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាលើ "សេចក្តីព្រាងបឋមគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃសន្និធិ" និង "សេចក្តីព្រាងបឋមគោលការណ៍ណែនាំស្តីពីឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូរប្រាក់រូបិយប័ណ្ណបរទេស" ដែលដឹកនាំដោយ **លោក ជា សុជាតិ** ប្រធាននាយកដ្ឋានគោលការណ៍គណនេយ្យនិងវិភាគការអនុវត្តថវិកា នៃអគ្គនាយកដ្ឋានរតនាគារជាតិ ដោយមានការចូលរួមពីតំណាងនិយ័តករគណនេយ្យនិងសវនកម្ម, អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ, អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល, អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមប្រព័ន្ធអនឡាញ។

## ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយថ្នាក់គ្រប់គ្រងរបស់សាកលវិទ្យាល័យពាណិជ្ជសាស្ត្រ អេស៊ីលីដា



១៦.កាលពីថ្ងៃអង្គារ ៤រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែវិច្ឆិកា គ.ស.២០២៤ នៅនិយ័តករគណនេយ្យ និងសវនកម្ម ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ណុប សម្បត្តិ** អនុប្រធាននាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម អមដោយ**លោក សាយ សុខខេង** ទីប្រឹក្សាបច្ចេកទេស និងមន្ត្រីជំនាញទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយថ្នាក់គ្រប់គ្រងរបស់សាកលវិទ្យាល័យពាណិជ្ជសាស្ត្រអេស៊ីលីដា។ គោលបំណងនៃជំនួបក្នុងថ្ងៃនេះគឺដើម្បីពិនិត្យនិងពង្រីកក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការដែលមានចែងក្នុងអនុស្សរណៈ និងជំរុញអនុវត្តការងារនៃកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា។

## កិច្ចប្រជុំលើកទី២ របស់ក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច



១៧.កាលពីថ្ងៃអង្គារ ៤ រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី ១៩ ខែវិច្ឆិកា គ.ស.២០២៤ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក ទឹម សត្យា** អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ និង **លោក ជីវ ហ៊ា** ប្រធានការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យា ដែលជាសមាជិកនៃក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច បានអញ្ជើញចូលរួមកិច្ចប្រជុំលើកទី២ របស់ក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដែលប្រព្រឹត្តទៅនៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កិច្ចប្រជុំពិភាក្សានេះ ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។

## កិច្ចពិភាក្សាជាមួយអង្គភាពសវនកម្មផ្ទៃក្នុងដើម្បីស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង




១៨.កាលពីថ្ងៃព្រហស្បតិ៍ ៦រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែវិច្ឆិកា គ.ស.២០២៤ នៅបន្ទប់ប្រជុំធំ និយ័តករគណនេយ្យនិងសវនកម្ម **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំ បានជួបពិភាក្សាជាមួយអង្គភាពសវនកម្មផ្ទៃក្នុង ក្រោមការដឹកនាំរបស់ **លោក ឈុំ សេរីរុធ** អនុប្រធាន

អង្គភាពសវនកម្មផ្ទៃក្នុង និងមន្ត្រីជំនាញ បានចុះដល់កន្លែងដើម្បីស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ព្រមទាំងស្វែងយល់ពីអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីរៀបចំផែនការសវនកម្ម ២០២៥។

## សិក្ខាសាលាបញ្ជ្រាបការយល់ដឹងស្តីពី "ស្តង់ដាគណនេយ្យនិងរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់អង្គការសង្គមស៊ីវិល



១៩.កាលពីថ្ងៃចន្ទ ១០រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែវិច្ឆិកា គ.ស.២០២៤ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម បានដឹកនាំគណៈប្រតិភូរបស់និយ័តករគណនេយ្យនិងសវនកម្ម ដើម្បីចូលរួមសិក្ខាសាលាបញ្ជ្រាបការយល់ដឹងស្តីពី"ស្តង់ដាគណនេយ្យនិងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គការសង្គមស៊ីវិល"។ សិក្ខាសាលានេះរៀបចំនិងសហការដោយ វេទិកាសម្ព័ន្ធសង្គមស៊ីវិល(វ.ស.ស.) និងនិយ័តករគណនេយ្យនិងសវនកម្ម នៅសាលទន្លេសាប អគារខេមរវិទូ នៃរាជបណ្ឌិតសភាកម្ពុជា។

## កិច្ចប្រជុំពិភាក្សា និងចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹងស្តង់ដាគណនេយ្យសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅកម្ពុជាជាមួយនិយ័តករសន្តិសុខសង្គម



២០.កាលពីថ្ងៃចន្ទ ១០រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែវិច្ឆិកា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ហេង សំណាង** ប្រធានការិយាល័យស្តង់ដាគណនេយ្យសាធារណៈនិងមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំពិភាក្សានិងចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹងស្តង់ដាគណនេយ្យសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅកម្ពុជាជាមួយនិយ័តករសន្តិសុខសង្គម ក្រោមការដឹកនាំរបស់ **លោក ឡេង សុខឡុង** ប្រធាននាយកដ្ឋានត្រួតពិនិត្យនិងមន្ត្រីជំនាញនៃនិយ័តករសន្តិសុខសង្គម នៅបន្ទប់ប្រជុំអគារ "ង" ជាន់ទី៥ នៃទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## កិច្ចប្រជុំពិភាក្សាជាមួយក្រុមប្រឹក្សានីតិកម្មដើម្បីពិភាក្សានិងស្វែងយល់ពីតម្រូវការរបស់និយ័តករគណនេយ្យនិងសវនកម្ម



២១.កាលពីថ្ងៃអង្គារ ១១រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែវិច្ឆិកា គ.ស.២០២៤ នៅបន្ទប់តូចប្រជុំអគារ "គ" នៃទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព អមដោយ មន្ត្រីជំនាញ បានជួបប្រជុំពិភាក្សាជាមួយក្រុមប្រឹក្សានីតិកម្ម ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ស៊ាង ផល្លា** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម អមដោយ **ឯកឧត្តម រស់ សុខណារុណ** អនុប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្មនិងមន្ត្រីជំនាញ ដើម្បីពិភាក្សានិងស្វែងយល់ពីតម្រូវការរបស់និយ័តករគណនេយ្យនិងសវនកម្ម ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។

## កិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាលើ "សេចក្តីព្រាងទម្រង់ និងមាតិកានៃរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាមមូលដ្ឋានសាច់ប្រាក់កែសម្រួល សម្រាប់ដំណាក់កាលទី២ (២០២៥ - ២០២៧)"




២២.កាលពីថ្ងៃពុធ ១២ រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែវិច្ឆិកា គ.ស.២០២៤ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស និងមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាលើ "សេចក្តីព្រាងទម្រង់និងមាតិកានៃរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាមមូលដ្ឋានសាច់ប្រាក់កែសម្រួល សម្រាប់ដំណាក់កាលទី២ (២០២៥ - ២០២៧)" ជាមួយតំណាងអគ្គនាយកដ្ឋានរតនាគារជាតិ និងទីប្រឹក្សាក្នុងស្រុក **លោក ខេស៊ី បាណេត** នៅបន្ទប់ប្រជុំធំនៃនិយ័តករគណនេយ្យនិងសវនកម្ម អគារ "ក" ជាន់ទី១ នៃទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## កិច្ចប្រជុំពិភាក្សាលើ "សេចក្តីព្រាងបឋមគោលការណ៍ណែនាំស្តីពីឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូរប្រាក់រូបិយប័ណ្ណបរទេស"




២៣.កាលពីថ្ងៃពុធ ១២រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែវិច្ឆិកា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ចារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ហេង សំណាង** ប្រធានការិយាល័យស្តង់ដាគណនេយ្យសាធារណៈ និងមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំពិភាក្សាលើ "សេចក្តីព្រាងបឋមគោលការណ៍ណែនាំស្តីពីឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូរប្រាក់រូបិយប័ណ្ណបរទេស" ដែលរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិជាមួយជំនាញការបារាំង ADF តាមប្រព័ន្ធអនឡាញ ។

## កិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាអំពី "តួនាទីនិងភារកិច្ចនិងការប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុក្រោមឆត្រគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុ (គ.ជ.ស.)"



២៤.កាលពីថ្ងៃពុធ ១២រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែវិច្ឆិកា គ.ស. ២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ចារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក លឹម ចាន់រតនៈ** សមាជិកក្រុមការងារស្ថិរភាពនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានចូលរួមកិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាអំពី "តួនាទីនិងភារកិច្ចនិងការប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុក្រោមឆត្រគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុ (គ.ជ.ស.)" ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា និងមានការអញ្ជើញចូលរួមពី ឯកឧត្តមរដ្ឋលេខាធិការ ឯកឧត្តមអនុរដ្ឋលេខាធិការ និងថ្នាក់ដឹកនាំ នៃនិយ័តករទាំងអស់ក្រោមឱវាទ នៅបន្ទប់ប្រជុំអគារ "គ" ជាន់ផ្ទាល់ដី នៃទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

## កិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគីជាមួយក្រុមការងារផ្នែកឯកជន នៃក្រុមការងារផ្នែកសេវាហិរញ្ញវត្ថុមិនមែនធនាគារ នៃសភាពាណិជ្ជកម្មកម្ពុជា



២៥.កាលពីថ្ងៃព្រហស្បតិ៍ ១៣រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែវិច្ឆិកា គ.ស.២០២៤ នៅអគារ "គ" នៃទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព មន្ត្រីជំនាញបានជួបប្រជុំពិគ្រោះយោបល់ទ្វេភាគីជាមួយក្រុមការងារផ្នែកឯកជននៃក្រុមការងារផ្នែកសេវាហិរញ្ញវត្ថុមិនមែនធនាគារ នៃសភាពាណិជ្ជកម្មកម្ពុជា ដែលដឹកនាំដោយ **ឧកញ៉ា លឹម សុជាតិ** អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា តំណាង **អ្នកឧកញ៉ា គិត ម៉េង** ប្រធានសភាពាណិជ្ជកម្មកម្ពុជា និងក្រុមការងារដើម្បីពិភាក្សាអំពីកម្រិតទំហំផលរបរ និងដើមទុនដែលបានកំណត់នៅក្នុង "សេចក្តីព្រាងប្រកាសស្តីពីកាតព្វកិច្ចដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ"។ កិច្ចប្រជុំនេះមានបំណងឱ្យសេចក្តីព្រាងប្រកាសនេះកាន់តែមានភាពពេញលេញ និងគ្រប់ជ្រុងជ្រោយស្របតាមស្មារតីនៃកិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២០ កាលពីថ្ងៃទី៤ ខែវិច្ឆិកា គ.ស.២០២៤ កន្លងទៅ។

## ទទួលជួបពិភាក្សាការងារជាមួយ លោក CA Charuhas D. Upasani សមាជិកជាន់ខ្ពស់ក្រុមអ្នកកំណត់ស្តង់ដាអាស៊ី-អូសេអានី ( AOSSG ) និងវិទ្យាស្ថានគណនេយ្យករឥណ្ឌា ( ICAI )




២៦.កាលពីថ្ងៃព្រហស្បតិ៍ ១៣រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែវិច្ឆិកា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស និងមន្ត្រីជំនាញ បានទទួលជួបពិភាក្សាការងារជាមួយ **លោក CA Charuhas D. Upasani** សមាជិកជាន់ខ្ពស់ក្រុមអ្នកកំណត់ស្តង់ដាអាស៊ី-អូសេអានី (AOSSG) និងវិទ្យាស្ថានគណនេយ្យករឥណ្ឌា (ICAI) ក្នុងគោលបំណងស្វែងរកភាពជាដៃគូរវាងនិយ័តករគណនេយ្យនិងសវនកម្ម និងវិទ្យាស្ថានគណនេយ្យករជំនាញឥណ្ឌា( ICAI )ដើម្បីអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជាឱ្យកាន់តែមានការរីកចម្រើន និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិ ក្នុងក្របខណ្ឌវិស័យគណនេយ្យនិងសវនកម្ម ឱ្យកាន់តែមានភាពទូលំទូលាយ។

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ"



២៧.កាលពីថ្ងៃព្រហស្បតិ៍ ១៣រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែវិច្ឆិកា គ.ស.២០២៤ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ" សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ។ សិក្ខាសាលានេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថាវិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំងវត្តមានរបស់តំណាងសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ចំនួន២០០នាក់។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយនិងបញ្ជ្រាបការយល់ដឹងអំពីកាតព្វកិច្ចគណនេយ្យនិងសវនកម្មនិងបទប្បញ្ញត្តិពាក់ព័ន្ធ។

## កម្មវិធីវិបស្សនារបស់ក្រុមការងារយេនឌ័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



២៨.កាលពីថ្ងៃព្រហស្បតិ៍ ១៣រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែវិច្ឆិកា គ.ស.២០២៤**លោកស្រី នាន បូនី** អគ្គនាយករង នៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាសមាជិកាក្រុមការងារបញ្ជ្រាបយេនឌ័រ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អមដោយ **លោកស្រី ថោ សេដ្ឋចាន់លីដា** និងមន្ត្រីជំនាញ បានអញ្ជើញចូលរួមកម្មវិធីវិបស្សនារបស់ក្រុមការងារយេនឌ័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានរៀបចំឡើងនៅសណ្ឋាគារសង្គហៈមិត្ត ខេត្តកែប ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ពី **លោកជំទាវ កែវ ចរិយា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានក្រុមការងារបញ្ជ្រាបយេនឌ័រ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ សមាសភាពចូលរួមក្នុងកម្មវិធីនេះរួមមានតំណាងអគ្គនាយកដ្ឋាន អង្គភាព មន្ទីរក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ គោលបំណងនៃកម្មវិធីវិបស្សនានេះរួមមាន ១.ពិនិត្យលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០២០-២០២៣ និងទិសដៅបន្ត ២.ពិភាក្សាលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០២៤-២០២៨ និង ៣.ទស្សនៈកិច្ចសិក្សានៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីខេត្តកែប និងខេត្តកំពតផងដែរ។

# សិក្ខាសាលាពិគ្រោះយោបល់លើផែនទីបង្ហាញផ្លូវនៃការចាប់យកឌីជីថលសម្រាប់ក្រុមហ៊ុនគណនេយ្យនិងសវនកម្ម ធុនតូចនិងមធ្យម



២៩.កាលពីថ្ងៃសុក្រ ១រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែវិច្ឆិកា គ.ស.២០២៤ **ឯកឧត្តម ម៉ិ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម បានចូលរួមជាអធិបតីភាព ដ៏ខ្ពង់ខ្ពស់ក្នុងការថ្លែងសុន្ទរកថាបើកក្នុងសិក្ខាសាលាពិគ្រោះយោបល់លើផែនទីបង្ហាញផ្លូវនៃការចាប់យកឌីជីថលសម្រាប់ក្រុមហ៊ុនគណនេយ្យនិងសវនកម្មធុនតូចនិងមធ្យម ដោយមានអ្នកចូលរួមចំនួន៧០នាក់ ដែលប្រព្រឹត្តទៅនៅសណ្ឋាគារហ៊ីម៉ាវ៉ារី។ សិក្ខាសាលាពិគ្រោះយោបល់នេះក៏បានទាញយកប្រយោជន៍អតិបរមាពីបច្ចេកវិទ្យាឌីជីថល រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា បានប្រកាសដាក់ឱ្យអនុវត្តនូវ «ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥» នៅឆ្នាំ២០២១។ រាជរដ្ឋាភិបាលក៏បានដាក់ឱ្យអនុវត្តនូវគោលនយោបាយអភិវឌ្ឍន៍បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា (២០២៣–២០២៨) ក្នុងឆ្នាំ២០២៣ ដើម្បី "អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុដោយឈរលើមូលដ្ឋាននៃការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និងការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ ដើម្បីចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និងផ្តល់កាលានុវត្តភាពដល់គ្រប់តួអង្គសំដៅរួមចំណែកជំរុញសន្ទុះនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាដ៏រស់រវើក"។

រៀបចំដោយ ÷ **លោក ឡាយ វិចិត្រ**

សម្របសម្រួលអត្ថបទ ÷ **កញ្ញា សុខ ណារី**

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម